MASSACHUSETTS DEPARTMENT OF ELEMENTARY & SECONDARY EDUCATION

MCAS

MASSACHUSETTS COMPREHENSIVE ASSESSMENT SYSTEM

*ប្រព័ន្ធការប៉ាន់ប្រមាណទូលំទូលាយ*

*នៃរដ្ឋម៉ាស្សាឈូសិត*

*(MCAS)*

# សេចក្តីណែនាំសម្រាប់មាតាបិតា និង អាណាព្យាបាល ស្តីពី 2008 MCAS

ក្រសួងសិក្សាធិការបឋមភូមិ និងទុតិយភូមិរដ្ឋ
ម៉ាស្សាឈូសិត

Massachusetts Department of
ELEMENTARY & SECONDARY
EDUCATION

ក្រសួងសិក្សាធិការបឋមភូមិ និងទុតិយភូមិរដ្ឋម៉ាស្សាឈូសិត

*ឯកសារនេះត្រូវបានរៀបចំឡើងដោយក្រសួងសិក្សាធិការបឋមភូមិ និងទុតិយភូមិរដ្ឋម៉ាស្សាឈូសិត*

Mitchell D. Chester, Ed.D., ស្នងការ ក្រសួងសិក្សាធិការបឋមភូមិ និងទុតិយភូមិ

# *បុព្វកថានៃស្នងការក្រសួងសិក្សាធិការ*

សូមជម្រាបចំពោះមាតាបិតា ឬ អាណាព្យាបាលជាទីមេត្រី !

ការប៉ាន់ប្រមាណសិស្ស MCAS ជាផ្នែកសំខាន់មួយនៃការខំប្រឹងប្រែងរបស់ខុម៉ុនវែលយើង ដើម្បីជួយដល់ការអប់រំរបស់សិស្សានុសិស្ស ។ ការប្រឡងទាំងអស់ រៀបចំឡើងដើម្បីប្រមាណអំពីការសិក្សាជំនាញ ចំណេះដឹង និងការអភិវឌ្ឍន៍សំខាន់ក្នុងមុខវិជ្ជាសិក្សាស្នូល ។ ពួកវាក៏ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញពីវិធីដែលសាលា និងមណ្ឌលកំពុងជួយសិស្សានុសិស្សសិក្សា និងកែលំអលទ្ធផលសិក្សារបស់ពួកគេ ។

សេចក្តីណែនាំនេះ រៀបចំឡើងដើម្បីជួយលោក-អ្នកក្នុងការរៀបចំពិនិត្យមើលឡើងវិញនូវ *Parent/Guardian Report* [*សេចក្តីណែនាំសម្រាប់មាតាបិតា និងអាណាព្យាបាល*] ដែលផ្តល់នូវលទ្ធផលនៃការប្រឡង MCAS របស់កូនលោក-អ្នកនៅរដូវផ្ការីកឆ្នាំ 2008 ។

បើសិនជាលោក-អ្នក មានសំណួរផ្សេងៗថែមទៀត ស្តីពីអត្ថន័យនៃលទ្ធផល ឬ កម្រិតការសិក្សារបស់កូន លោក-អ្នក ខ្ញុំសូមលើកទឹកចិត្តលោក-អ្នក ឱ្យអញ្ជើញទៅជួបគ្រូៗរបស់កូនលោក-អ្នក ដើម្បីពិភាក្សាពីលទ្ធផលទាំងនោះ ហើយនិងរិះរកមធ្យោបាយយ៉ាងណា ដែលអាចឱ្យលោក-អ្នកធ្វើសហការជាមួយសាលាដើម្បីជួយដល់ការសិក្សា របស់កូនលោក-អ្នក ។ ជំនួយរបស់លោក-អ្នកគឺមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការជួយកូនរបស់លោក-អ្នក ឱ្យបានសម្រេចជោគជ័យនៅសាលារៀន និងក្នុង ការពង្រឹងការអប់រំសម្រាប់សិស្សានុសិស្សនៃរដ្ឋម៉ាស្សាឈូសិត ។

ដោយសេចក្តីស្មោះស្ម័គ្រ !

Mitchell D. Chester, Ed. D.
ស្នងការក្រសួងសិក្សាធិការបឋមភូមិ និងទុតិយភូមិ

Copyright © 2008 Massachusetts Department of Elementary and Secondary Education
តាមរយៈនេះ ការអនុញ្ញាតឱ្យចម្លងផ្នែកខ្លះ ឬ គ្រប់ផ្នែកទាំងអស់នៃឯកសារនេះ សម្រាប់គោលបំណងអប់រំមិន មានលក្ខណៈពាណិជ្ជកម្ម ។
សូមផ្តល់កិត្តិយសចំពោះ “Massachusetts Department of Elementary and Secondary Education” ។

**ឯកសារនេះ បានបោះពុម្ពដោយប្រើក្រដាសយកប្រើម្តងទៀត ។**

350 Main Street, Malden, Massachusetts 02148-5023
781-338-3000
www.doe.mass.edu

# មាតិការឿង

*បុព្វកថានៃស្នងការក្រសួងសិក្សាធិការ*


**I. តើគោលបំណងរបស់ MCAS ប្រព័ន្ធការប៉ាន់ប្រមាណទូលំទូលាយនៃរដ្ឋម៉ាស្សាឈូសិត មានអ្វីខ្លះ ? ......2**
សេចក្ដីណែនាំស្ដីអំពីការចូលរួម ......2
សិស្សដែលរៀនធ្លាក់ ......2
សិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP) ......3

**II. តើការប្រឡង MCAS អ្វីខ្លះដែលបានសួរពិនិត្យនៅ ឆ្នាំ 2008 នេះ ? ......4**
ការប្រឡងនៅរដូវផ្ការីកឆ្នាំ 2008 ......4
ការប្រឡងសារជាថ្មី ......5

**III. តើសំណួរប្រភេទអ្វីខ្លះ ដែលមាននៅក្នុងការប្រឡង MCAS ? ......5**

**IV. តើគេនឹងប្រើប្រាស់លទ្ធផលការប្រឡងរបស់កូនលោក-អ្នកយ៉ាងដូចម្ដេច ? ......6**

**V. តើលទ្ធផលនៃ MCAS រាយការណ៍យ៉ាងដូចម្ដេច ? ......8**
ក. ផ្នែកទី I: ពិន្ទុរបស់កូនលោក-អ្នក ......8
កម្រិតលទ្ធផលនៃការប្រឡង ......8
មាត្រដ្ឋានពិន្ទុ ......9
ការបង្ហាញពិន្ទុ និង លំដាប់ពិន្ទុប្រហាក់ប្រហែល (ថ្នាក់ទី 4–8 និងទី 10) ......9
ការបង្ហាញពិន្ទុរបស់សិស្សនៅក្នុងលំដាប់កម្រិតលទ្ធផល (ថ្នាក់ទី 3) ......9
ការបង្ហាញពិន្ទុ និងលំដាប់ពិន្ទុប្រហាក់ប្រហែល (ថ្នាក់ទី 9) ......9
ខ. ផ្នែកទី II: ព័ត៌មានអំពីលទ្ធផលរបស់កូនលោក-អ្នកចំពោះសំណួរប្រឡង MCAS ......10
គ. ផ្នែកទី III: តើពិន្ទុរបស់កូនលោក-អ្នក ប្រៀបធៀបទៅនឹងពិន្ទុសាលា មណ្ឌល និង រដ្ឋយ៉ាងដូចម្ដេចដែរ ? ......11
ឃ. ឃ. ផ្នែកទី IV: ព័ត៌មានបន្ថែម ......11
សម្រាប់ថ្នាក់ទី 4 ទី 7 និង ទី 10 ប៉ុណ្ណោះ : ការពណ៌នាស្ដីពីការបំពេញកិច្ចការអនុវត្តន៍ផ្នែកសរសេររបស់កូនលោក-អ្នក ......11
សម្រាប់ថ្នាក់ទី 9 ប៉ុណ្ណោះ: ភាគរយនៃសិស្សនៅក្នុងថ្នាក់នាឆ្នាំ 2011 ដែលបានចូលរួមក្នុងការប្រឡង STE ថ្នាក់មធ្យមសិក្សា ......11
ង. តើព័ត៌មានអ្វីខ្លះដែល *សេចក្ដីណែនាំសម្រាប់មាតាបិតា និងអាណាព្យាបាល* ផ្ដល់ឱ្យ ប្រសិន បើកូនរបស់អ្នកបានចូលរួមក្នុងការវាយតម្លៃជម្រើស ? ......11
ច. ក្នុងលក្ខខណ្ឌបែបណាដែលកូនសិស្សមួយណា មិនបានទទួលពិន្ទុ MCAS ? ......12

**VI. តើខ្ញុំអាចរកព័ត៌មានថែមទៀតនៅឯណា ? ......12**
ក. របាយការណ៍បន្ថែមដែលមាន ......12
ខ. ប្រភពជំនួយផ្សេងទៀត ......12
គ. តើលោក-អ្នកអាចធ្វើអ្វីដើម្បីជួយកូនលោក-អ្នក ? ......13

# I. តើគោលបំណងរបស់ MCAS ប្រព័ន្ធការវាយតម្លៃប្រមាណទូលំទូលាយ នៃរដ្ឋម៉ាសាឈូសិត មានអ្វីខ្លះ ?

Massachusetts Comprehensive Assessment System [ប្រព័ន្ធការប៉ាន់ប្រមាណទូលំទូលាយនៃរដ្ឋម៉ាស្សាឈូសិត] (MCAS) បានបង្កើតឡើងសម្របតាមការតម្រូវនៃ Education Reform Law [ច្បាប់កែទម្រង់សិក្សាធិការ] ឆ្នាំ 1993 ច្បាប់នេះចែងថា កម្មវិធីប្រឡងត្រូវតែ :

- ឱ្យសិស្សានុសិស្ស *ទាំងអស់* រៀននៅសាលារដ្ឋនៃរដ្ឋម៉ាស្សាឈូសិតធ្វើការប្រឡង ដោយរាប់បញ្ចូលទាំងសិស្ស ដែលរៀនធ្លាក់ និង limited English proficient [សិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់] ។
- ប៉ាន់ប្រមាណសមត្ថភាពរបស់សិស្សម្នាក់ៗ ដោយអនុលោមទៅតាមលក្ខខណ្ឌសិក្សានៃ *Curriculum Framework* [*គំរោងកម្មវិធីសិក្សា*] នៃរដ្ឋម៉ាស្សាឈូសិត ។
- រាយការណ៍អំពីសមត្ថភាពរបស់សិស្សម្នាក់ៗ សាលារៀននិមួយៗ និង មណ្ឌលនិមួយៗ ។

ដូចបានតម្រូវដោយច្បាប់កែទម្រង់សិក្សាធិការ សិស្សទាំងឡាយត្រូវតែប្រឡងជាប់ថ្នាក់ទី 10 នៃ English Language Arts [អក្សរសិល្ប៍អង់គ្លេស] (ELA) និង គណិតសាស្ត្រ ស្របជាមួយនិងការប្រឡងមួយក្នុងចំណោមការប្រឡងទាំងបួនថ្នាក់មធ្យមសិក្សាក្នុងមុខវិជ្ជា Science and Technology/Engineering [វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម] (STE) ដែលជាលក្ខខណ្ឌសម្រាប់ជាសិទ្ធិទទួលសញ្ញាប័ត្រមធ្យមសិក្សា (បន្ថែមទៅលើការបំពេញតម្រូវការមូលដ្ឋាន) ។

ជាងនេះទៅទៀត កម្មវិធី MCAS ត្រូវបានប្រើប្រាស់ដើម្បីរៀបចំឱ្យសាលា និង មណ្ឌលទទួលខុសត្រូវជាមូលដ្ឋាន ប្រចាំឆ្នាំសម្រាប់ការចម្រើនលូតលាស់ដែលគេបានធ្វើឆ្ពោះទៅកាន់គោលដៅនៃ No Child Left Behind Law [គ្មានសិស្សណាម្នាក់រៀននៅក្រោយកម្មវិធី] ឱ្យមានភាពស្ទាត់ជំនាញក្នុងការអាន និងគណិតវិទ្យានៅឆ្នាំ 2014 ។

## *សេចក្តីណែនាំស្តីអំពីការចូលរួម*

នៅក្នុងឆ្នាំ 2008 សិស្សសាលារដ្ឋទាំងអស់ ចាប់ពីថ្នាក់ទី 3 រហូតដល់ថ្នាក់ទី 8 និងថ្នាក់ទី 10 ត្រូវចូលរួមប្រឡង MCAS ដែលអាចទទួលបាននៅកម្រិតថ្នាក់របស់ពួកគេ ។ សាលាក៏ត្រូវរៀបចំការប្រឡងឱ្យសិស្សានុសិស្សថ្នាក់ទី 9 ណាដែលបានចុះឈ្មោះក្នុងមុខវិជ្ជាជីវវិទ្យា គីមីវិទ្យា រូបវិទ្យាមូលដ្ឋាន ឬបច្ចេកវិទ្យា/វិស្វកម្ម ហើយនិងអ្នកដែលជ្រើសរើសចូលរួមក្នុងការប្រឡង MCAS ដែលមានតម្លៃប្រហាក់ប្រហែលគ្នា ។

## សិស្សដែលរៀនធ្លាក់

ក្នុងរយៈពេលមួយឆ្នាំ មុនពេលធ្វើការវាយតម្លៃទូទាំងរដ្ឋដែលបានគ្រោងទុក Individualized Education Program [កម្មវិធីអប់រំជាលក្ខណៈបុគ្គល] (IEP) ឬ ក្រុមការងារ 504 បានជួបជុំគ្នា សម្រេចអំពីរបៀបចូលរួមក្នុងការ ប្រឡង MCAS របស់សិស្សដែលរៀនធ្លាក់ម្នាក់ៗ ។ ព័ត៌មាននេះត្រូវបានធ្វើជាឯកសារនៅក្នុង IEP ឬ ផែនការ 504 របស់សិស្ស ។

សម្រាប់សិស្សដែលរៀនធ្លាក់ ដែលមិនអាចប្រឡង MCAS ជាធម្មតាបាន ទោះបីជាមាន ឬ ក៏គ្មានការសម្រប សម្រួលពីសាលាទេ នោះក្រសួងសិក្សាធិការនឹងត្រួតពិនិត្យ Alternate Assessment [ការវាយតម្លៃជម្រើស] របស់ MCAS ។ មាតាបិតារបស់សិស្សដែលចូលរួមក្នុងការវាយតម្លៃជម្រើសនឹងទទួល *របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល* ពីរ មួយ ជារបាយការណ៍ធម្មតាដែលបញ្ជាក់ថា សិស្សបានទទួលយកការវាយតម្លៃជម្រើស និង បង្ហាញពីកម្រិតស្នាដៃរបស់សិស្ស និង របាយការណ៍មួយទៀតបង្ហាញពីព័ត៌មានលំអិតពីស្នាដៃរបស់សិស្សលើការវាយតម្លៃជម្រើស ។

លទ្ធផល MCAS របស់សិស្សដែលរៀនធ្លាក់ រួមទាំងសិស្សដែលចូលរួមក្នុងការវាយតម្លៃជម្រើស នឹងត្រូវបាន បញ្ចូលទៅក្នុងលទ្ធផលរបស់សាលា មណ្ឌល និង រដ្ឋ ។

ព័ត៌មានបន្ថែមអំពីសេចក្តីតម្រូវក្នុងការចូលរួមប្រឡង និង លទ្ធភាពផ្សេងៗ ដែលសាលាអាចរៀបចំសម្របសម្រួលបាន អាចរកឃើញនៅក្នុងឯកសារ *Requirements for the Participation of Students with Disabilities in MCAS* [*តម្រូវការនៃការចូលរួមរបស់សិស្សដែលរៀនធ្លាក់ក្នុង MCAS*] ដែលមាននៅលើវិបសាយរបស់ក្រសួងតាមអាសយដ្ឋាន www.doe.mass.edu/mcas/participation ។

## សិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP)

សិស្ស LEP " គឺជាសិស្សដែលមានភាសាកំណើតមិនមែនជាភាសាអង់គ្លេស " ដែលពុំអាចបំពេញកិច្ចការសាលាធម្មតាជាភាសាអង់គ្លេសបាន " ។ ការចាត់ទុកសិស្សថា មានលក្ខណៈLEP ត្រូវបានធ្វើឡើងស្របតាមរបៀបសំគាល់លក្ខណៈនៃមណ្ឌល ។

បញ្ញត្តិនៃច្បាប់សហព័ន្ធ និង រដ្ឋ តម្រូវថាសិស្ស LEP *ទាំងអស់* ដែលបានចុះឈ្មោះរៀននៅសាលារដ្ឋនៃ រដ្ឋម៉ាស្សាឈូសិត និង នៅសាលាឯកជនដែលរដ្ឋបង់ថ្លៃឱ្យត្រូវតែចូលរួមប្រឡង MCAS ផ្នែក គណិតសាស្ត្រ និង STE ដែលបានផ្តល់តាមកម្រិតថ្នាក់របស់គេ ។ សម្រាប់សិស្ស LEP ក្នុងឆ្នាំដំបូង នៃការចុះឈ្មោះរបស់ពួកគេក្នុងសាលារដ្ឋរបស់ សហរដ្ឋអាមេរិក មណ្ឌលមានជម្រើសឱ្យសិស្សចូលរួមក្នុងការប្រឡង ELA នៅតាមកម្រិតថ្នាក់របស់ពួកគេ ។ លទ្ធផលសម្រាប់សិស្ស LEP ឆ្នាំដំបូង ត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងវិភាគប៉ុណ្ណោះ ។ ហេតុនេះ សិស្សទាំងនេះមិនបានទទួលមាត្រដ្ឋានពិន្ទុ និងកម្រិតលទ្ធផលនៃការប្រឡងនោះទេ ។

ជាងនេះទៅទៀត សិស្ស LEP ទាំងអស់ត្រូវបានតម្រូវឱ្យចូលរួមក្នុង Massachusetts English Proficiency Assessment Reading/Writing [ការវាយតម្លៃភាពស្ទាត់ជំនាញភាសាអង់គ្លេសរដ្ឋម៉ាស្សាឈូសិត-អំណាន/ការសរសេរ] (MEPA-R/W) និង Massachusetts English Language Assessment-Oral [ការវាយតម្លៃភាសាអង់គ្លេសរដ្ឋម៉ាស្សាឈូសិត-ផ្ទាត់មាត់] (MELA-O) ដើម្បីវាស់វែងពីការរីកចម្រើនប្រចាំឆ្នាំរបស់ពួកគេចំពោះ ការសិក្សាភាសាអង់គ្លេស ។ ក្នុងនិទាឃរដូវ ឆ្នាំ 2008 សិស្ស LEP ពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី 2 ក្នុងមណ្ឌលតាមថាយថល III ក៏ត្រូវចូលរួមក្នុងការវាយតម្លៃការអាន និងការសរសេរ ដែលត្រូវបានហៅថាជា IDEA Proficiency Test [ការប្រឡងភាពជំនាញ IDEA] (IPT) ។

ក្នុងឆ្នាំ 2008 សិស្ស LEP ដែលនិយាយភាសាអេស្ប៉ាញមានសិទ្ធិទទួលបានការចុះឈ្មោះរៀននៅ សហរដ្ឋអាមេរិកចំនួនតិចជាងបីឆ្នាំ មានជម្រើសប្រឡងគណិតសាស្ត្រថ្នាក់ទី 10 ជាពីរភាសាអង់គ្លេស/ភាសាអេស្ប៉ាញ បើគេអាចអាន និងសរសេរភាសាអេស្ប៉ាញស្មើ ឬ ក្បែរនឹងកម្រិតថ្នាក់ ។

ព័ត៌មានបន្ថែមអំពីសេចក្តីណែនាំក្នុងការចូលរួមនៃសិស្ស LEP អាចរកឃើញនៅក្នុងឯកសារ *Requirements for the Participation of Students with Limited English Proficiency in MCAS and MEPA* [*សេចក្តីត្រូវការចូលរួមប្រឡងនៃសិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ក្នុង MCAS និង MEPA*] ដែលមាននៅលើវិបសាយរបស់ក្រសួងតាមអាសយដ្ឋាន www.doe.mass.edu/mcas/participation ។

# II. *តើការប្រឡង MCAS អ្វីខ្លះដែលបានសួរពិនិត្យនៅ ឆ្នាំ2008 នេះ ?*

## ការប្រឡងនៅរដូវផ្ការីកឆ្នាំ 2008

តារាងខាងក្រោមបង្ហាញពីការប្រឡង MCAS 2008 ដែលត្រួតពិនិត្យនៅកម្រិតថ្នាក់និមួយៗ ។

| | |
|---|---|
| ថ្នាក់ទ 3 | ELA Reading Comprehension [ELA អំណាន]<br>Mathematics [គណិតវិទ្យា] |
| ថ្នាក់ទី 4 | ELA(Composition; Reading Comprehension) [ELA (តែងសេចក្តី អំណាន)]<br>គណិតវិទ្យា |
| ថ្នាក់ទី 5 | ELA អំណាន<br>គណិតវិទ្យា<br>Science and Technology/Engineering [វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម]<br>History and Social Science [ប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រសង្គម] * |
| ថ្នាក់ទី 6 | ELA អំណាន<br>គណិតវិទ្យា |
| ថ្នាក់ទី 7 | ELA (តែងសេចក្តី អំណាន)<br>គណិតវិទ្យា<br>ប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រសង្គម * |
| ថ្នាក់ទ 8 | ELA អំណាន<br>គណិតវិទ្យា<br>វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម |
| ថ្នាក់ទី 10 | ELA (តែងសេចក្តី អំណាន)<br>គណិតវិទ្យា |
| មធ្យមសិក្សា | វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម<br>• Biology [ជីវវិទ្យា]<br>• Chemistry [គីមីវិទ្យា]<br>• Introductory Physics [រូបវិទ្យាមូលដ្ឋាន]<br>• Technology/Engineering [បច្ចេកវិទ្យា/វិស្វកម្ម]<br>U.S. History [ប្រវត្តិសាស្ត្រអាមេរិក]* |

* មិនមានលទ្ធផលរបស់សិស្ស សាលា ឬថ្នាក់មណ្ឌល ត្រូវបានធ្វើឡើងដោយផ្អែកតាមការប្រឡងសាកល្បងប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រសង្គម ឬប្រវត្តិសាស្ត្រអាមេរិកនោះទេ ។

### ការប្រឡងសាជាថ្មី

នៅរដូវស្លឹកឈើជ្រុះ និង រដូវផ្ការីកម្តងៗ ក្រសួងនឹងផ្តល់ឱកាសឱ្យសិស្សថ្នាក់ទីដប់មួយ និង ទីដប់ពីរ ព្រមទាំងជនពេញវ័យដែលបានបញ្ចប់មធ្យមសិក្សា ដើម្បីចូលរួម MCAS retests [ប្រឡង MCAS ម្តងទៀត] ។ សិស្សទាំងអស់ ដែលមិនទាន់បានទទួល Competency Determination [ការអនុម័តថាមានសមត្ថភាព] អាចមានសិទ្ធិចូលរួមប្រឡង MCAS ក្នុងវិស័យ ELA និង ការប្រឡងគណិតសាស្រ្តសាជាថ្មីក្នុងកំឡុងឆ្នាំកន្លងទៅ ។

សិស្សថ្នាក់ទីដប់មួយដែលព្យាយាមធ្វើឱ្យពិន្ទុក្នុងការប្រឡង MCAS បានប្រសើរជាងមុន ដើម្បីឱ្យមានសិទ្ធិបានទទួល Certificate of Mastery [សញ្ញាបត្រចេះដឹង] ត្រូវបានអនុញ្ញាតឱ្យចូលរួមប្រឡងតាមមាត្រដ្ឋាន MCAS ឆ្នាំ 2008 ថ្នាក់ទី 10 នៃ ELA និង ការប្រឡងគណិតសាស្រ្ត ។ សិស្សថ្នាក់ទី 11 ផ្សេងទៀត ដែលអវត្តមានត្រូវបានកតត្រាទុកដោយសារសុខភាពសម្រាប់ការប្រឡងថ្នាក់ទី 10 ឬ ដែលត្រូវបានផ្ទេរទៅកាន់សាលារដ្ឋនៃរដ្ឋម៉ាស្សាឈូសិត បន្ទាប់ពីថ្នាក់ទី 10 ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុង ការប្រឡង MCAS ថ្នាក់ទី 10 ឆ្នាំ 2008 តាមបទដ្ឋាន ដើម្បព្យាយាមបំពេញលក្ខណៈសម្បត្តិសម្រាប់ John and Abigail Adams Scholarship [អាហារូបករណ៍ John and Abigail Adams] ។

## III. *តើសំណួរប្រភេទអ្វីខ្លះ ដែលមាននៅក្នុងការប្រឡង MCAS ?*

ការប្រឡង MCAS ប្រើទ្រង់ទ្រាយសំណួរច្រើនយ៉ាង ដើម្បីប៉ាន់ប្រមាណពីការសិក្សារបស់សិស្ស ។

- **Multiple-choice questions [សំណួរ-រើសចម្លើយ]** ត្រូវបានប្រើនៅក្នុងសំណួរគ្រប់មុខវិជ្ជា លើកលែងតែផ្នែកតែងសេចក្តី (ELA) ។ សិស្សរើសចម្លើយត្រូវ ក្នុងចំណោមចម្លើយផ្តល់ឱ្យទាំងបួន ។

  ចម្លើយត្រូវគឺបានផ្តល់ឱ្យពិន្ទុ 1 និង ចម្លើយខុសគឺបានផ្តល់ឱ្យពិន្ទុ 0 ។

- **Open-response questions [សំណួរ-ចម្លើយចំហរ]** ត្រូវបានប្រើនៅក្នុងសំណួរគ្រប់មុខវិជ្ជា លើកលែងតែការប្រឡងតែងសេចក្តី (ELA) ។ យោងទៅតាមមុខវិជ្ជាដែលបានប្រឡងនោះ សិស្សបង្កើតចម្លើយដោយសរសេរដែលមានតែមួយវគ្គ ឬ ច្រើនវគ្គ និង/ឬ គូសផែនទី តារាង ឌីយ៉ាក្រាម គូសរូបភាពសម្រាប់ពន្យល់ ឬ គំនូសតាង ។

  ពិន្ទុត្រូវបានផ្តល់ឱ្យផ្អែកតាមការណែនាំឱ្យពិន្ទុដែលកំណត់ឱ្យចំពោះសំណួរ-ចម្លើយចំហរនិមួយៗ ។ សម្រាប់តែគណិតវិទ្យាថ្នាក់ទី 3 ចម្លើយនិមួយៗទទួលពិន្ទុពី 0–2 ។ សម្រាប់ថ្នាក់ផ្សេងទៀត និង គ្រប់មុខវិជ្ជាទាំងអស់ ចម្លើយនិមួយៗទទួលពិន្ទុពី 0–4 ។

- **Short-answer questions [សំណួរ-ចម្លើយខ្លី]** ត្រូវបានប្រើនៅតែក្នុងសំណួរខាងគណិតសាស្រ្តប៉ុណ្ណោះ ។ សិស្សបញ្ចេញចម្លើយខ្លី តាមធម្មតាចម្លើយជាលេខ ឬ សេចក្តីថ្លែងខ្លីមួយ ។

  ចម្លើយត្រូវគឺបានពិន្ទុ 1 និង ចម្លើយខុសគឺបានពិន្ទុ 0 ផ្អែកតាមការណែនាំផ្តល់ពិន្ទុ ។

- **Writing prompts [តែងសេចក្តីតាមប្រធានផ្តល់ឱ្យ]** មាននៅផ្នែកតែងសេចក្តីអក្សរសិល្បឹអង់គ្លេស (ELA) ។ នៅគ្រប់កម្រិតថ្នាក់ឱ្យប្រឡង សិស្សសរសេរតែងសេចក្តីឆ្លើយតបតាមប្រធានដែលសរសេរផ្តល់ឱ្យ ។

  ការប្រឡងតែងសេចក្តីអក្សរសិល្បឹអង់គ្លេស (ELA) បានឱ្យធ្វើពីរពេលក្នុងថ្ងៃតែមួយ ដោយបានសម្រាក បន្តិចរវាងពេលទាំងពីរ ។ ពេលទីមួយ សិស្សសរសេររៀបចំព្រាងជាដំបូង ដែលមិនទាន់ឱ្យពិន្ទុឆ្លើយតប តាមប្រធានដែលបានផ្តល់ឱ្យនៃការសរសេររបស់គេ ។ បន្ទាប់ពីសម្រាក សិស្សត្រឡប់មកដើម្បីកែការសរសេរព្រាងទៅជាការបញ្ចប់នៃការសរសេរតែងសេចក្តី ហើយប្រគល់ទៅឱ្យមេប្រយោគដើម្បីឱ្យពិន្ទុ ។

  ការសរសេរតែងសេចក្តីអក្សរសិល្បឹអង់គ្លេស (ELA) និមួយៗទទួលពិន្ទុ ដោយអ្នកផ្តល់ពិន្ទុពីរនាក់ ផ្អែកតាមការណែនាំផ្តល់ពិន្ទុ ក្នុងពីរវិស័យដូចខាងក្រោម :

  - Topic Development [រៀបរាប់តាមប្រធាន] (ពិន្ទុ 2 ទៅ 12)
  - Standard English Conventions [ប្រើក្បួនខ្នាតភាសាអង់គ្លេស] (ពិន្ទុ 2 ទៅ 8)

# IV. *តើគេនឹងប្រើប្រាស់លទ្ធផលប្រឡងរបស់កូនលោក-អ្នកយ៉ាងដូចម្តេច ?*

នៅពេលលោក-អ្នកពិនិត្យមើលលទ្ធផលរបស់កូនលោក-អ្នក សូមចងចាំចំណុចខាងក្រោមនេះ :

- *របាយការណ៍សម្រាប់មាតាបិតា/អាណាព្យាបាល* ផ្តល់ឱ្យនូវព័ត៌មានសំខាន់អំពីការសិក្សារបស់កូនលោក-អ្នក នៅក្នុងមុខវិជ្ជាដែលសួរក្នុងពេលប្រឡង MCAS នៅឆ្នាំ 2008 ។ សូមប្រើប្រាស់លទ្ធផលពីការប្រឡង MCAS រួមគ្នាជាមួយការវាយតម្លៃរបស់គ្រូ និង កិច្ចការធ្វើនៅសាលារៀនពីមួយថ្ងៃទៅមួយថ្ងៃរបស់កូនលោក-អ្នក ដើម្បីប៉ាន់ប្រមាណថាតើកូនលោក-អ្នកធ្វើកិច្ចការបានល្អយ៉ាងណានៅសាលារៀន ។ ចំណាប់អារម្មណ៍ និង ការលើកទឹកចិត្តរបស់លោក-អ្នក គឺមានសារៈសំខាន់ណាស់ ។
- *របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល* ស្តីពី MCAS របស់កូនលោក-អ្នក ត្រូវបានចាត់ទុកថាជាផ្នែកនៃសំណុំរឿងសិស្សបណ្តោះអាសន្នរបស់កូនលោក-អ្នក ។ សំណុំរឿងសិស្សបណ្តោះអាសន្នរបស់កូនលោក-អ្នក រួមមាននូវព័ត៌មានទាំងអស់ដែលកត់ចុះក្នុងសំណុំប្រវត្តិរៀនសូត្រដែលសាលារក្សាទុកអំពីកូនលោក-អ្នក ដែលមាននៅក្នុងសៀវភៅសិក្ខាគារិករបស់គេទេ ។ ជាទូទៅ សំណុំរឿងសិស្សទាំងនេះ មិនអាចពិនិត្យមើលបានដោយនរណាម្នាក់ ក្រៅពីសិស្ស មាតាបិតា ឬ អាណាព្យាបាល និង បុគ្គលិក សាលារៀនដែលមានការអនុញ្ញាត ដោយគ្មានការយល់ព្រមពីមាតាបិតា ឬ អាណាព្យាបាលសិស្សបានឡើយ ។ គេនឹងកំទេចចោលសំណុំរឿងបណ្តោះអាសន្នរបស់សិស្សនៅពេលមិនយូរជាងប្រាំឆ្នាំ បន្ទាប់ពីពេលដែលសិស្សប្តូរសាលា ប្រឡងជាប់បានសញ្ញាប័ត្រ ឬ ក៏ចាកចេញពីប្រព័ន្ធសាលារៀន។ ដើម្បីបានព័ត៌មានបន្ថែមអំពីរឿងនេះ សូមមើលវ៉ិបសាយរបស់ក្រសួងសិក្សាធិការតាមអាសយដ្ឋាន www.doe.mass.edu ។
- ចាប់ផ្តើមពីឆ្នាំ 2010 ជាតម្រូវការមួយសម្រាប់ការទទួលបានសញ្ញាប័ត្រមធ្យមសិក្សា សិស្សត្រូវបានតម្រូវឱ្យបំពេញបាន ឬលើស scaled score [មាត្រដ្ឋានពិន្ទុ] 240 ពិន្ទុ (*Proficient*) [*ជំនាញ*] លើការប្រឡង MCAS វិស័យ ELA និងគណិតសាស្ត្រថ្នាក់ទី 10 ឬទទួលបានមាត្រដ្ឋានពិន្ទុ 220–238 (*Needs Improvement*) [*ខំរៀនថែមទៀត*] ទៅលើទាំងការប្រឡង និងការបំពេញតាមតម្រូវរបស់ Educational Proficiency Plan [ផែនការភាពជំនាញសិក្សាធិការ] (សូមមើល www.doe.mass.edu/hsreform/epp) ។ សិស្សានុសិស្សនៅក្នុងឆ្នាំ 2010 ត្រូវតែបំពេញបាន ឬលើស មាត្រដ្ឋានពិន្ទុ 220 លើការប្រឡងមួយក្នុងចំណោមការប្រឡង STE ថ្នាក់មធ្យមសិក្សាទាំងបួន ។ បន្ថែមពីលើការប្រឡង

MCAS ឱ្យជាប់ សិស្សានុសិស្សត្រូវបំពេញសេចក្តីតម្រូវនៃតំបន់ ដើម្បីឱ្យបានសញ្ញាប័ត្រមធ្យមសិក្សា ។ បើកូនលោក-អ្នកមិនបាន ពិន្ទុ 220 ឬច្រើនជាងនៅពេលប្រឡង MCAS វិស័យ ELA និង/ឬគណិតសាស្រ្តថ្នាក់ទី 10 កូនរបស់លោក-អ្នកនឹងមានឱកាសច្រើនដងដើម្បីចូលរួមក្នុងការប្រឡងឡើងវិញ សម្រាប់មុខវិជ្ជាដែលមិនបានជាប់ ។ ឱកាសដើម្បីប្រឡងមុខវិជ្ជាជីវវិទ្យាថ្នាក់មធ្យមសិក្សា នឹងត្រូវបានផ្តល់ឱ្យពីរដងក្នុងមួយឆ្នាំ ដោយចាប់ផ្តើមពីឆ្នាំ 2009: លើកដំបូងក្នុងខែកុម្ភៈ និងម្តងទៀតនៅចុងវគ្គសិក្សានានិទាឃរដូវ ។

- លទ្ធផល ELA និង គណិតសាស្រ្តពីសិស្សរៀនថ្នាក់ទី 10 (និង សម្រាប់សិស្សថ្នាក់ទី 11 ដែលពុំបានចូលរួមពីមុននៅថ្នាក់ទី 10 នៃ ELA និង/ឬការប្រឡងគណិតសាស្រ្ត) ត្រូវបានប្រើដើម្បីសម្រេចពីសិទ្ធិទទួលសម្រាប់ប្រាក់ជំនួយផ្តល់ឱ្យនិស្សិតពី John និង Abigail Adams ។ សិស្សមធ្យមសិក្សាសាលារដ្ឋម៉ាស្សាឈូសិត មានគុណសម្បត្តិសម្រាប់ប្រាក់ជំនួយផ្តល់ឱ្យនិស្សិតពី Adams បើសិនជា លទ្ធផលរបស់គេបំពេញតាមតម្រូវការបីខាងក្រោមនេះ:

    1. បានពិន្ទុផ្នែក *Advanced* [*ជឿនលឿន*] ក្នុងមួយណាក៏បាន ជាថ្នាក់ទី 10 នៃ ELA ឬ ជា ជាគណិតសាស្រ្ត
    2. បានពិន្ទុផ្នែក ជំនាញ ឬ *ជឿនលឿន* ក្នុងមុខវិជ្ជាទីពីរ (ELA *ឬជាគណិតសាស្រ្ត*) និង
    3. បានពិន្ទុ MCAS រួមគ្នានៅលើការប៉ាន់ប្រមាណដែលដាក់សិស្សក្នុងផ្នែកខាងលើ 25 ភាគរយនៅក្នុងសាលារៀនមណ្ឌលរបស់គេ ។

    សិស្សនៅក្នុងសាលាដែលមានច្បាប់អនុញ្ញាត និងសិស្សដែលបានចូលរួមក្នុងជម្រើសរបស់សាលា ឬ METCO មានសិទ្ធិទទួលបានអាហារូបករណ៍ ប្រសិនបើពួកគេបំពេញបានតាមតម្រូវការសិទ្ធិទទួលបានសម្រាប់សាលាដែលពួកគេចូលរៀន ឬ មណ្ឌលដែលពួកគេរស់នៅ ។

- ក្រុមអ្នកអប់រំប្រើលទ្ធផលរបស់សិស្ស សាលា និង មណ្ឌល ដ៏ច្រើនសន្ធឹកសន្ធាប់នេះ ដើម្បីពិនិត្យមើលឡើងវិញ នូវកម្មវិធី និងការបង្ហាត់បង្រៀន និងគំរោងការណ៍សម្រាប់ធ្វើឱ្យល្អប្រសើរ ។ នេះជាផ្នែកមួយនៃការបំពេញគោលបំណងនៃច្បាប់កែទម្រង់ការសិក្សា ដែលមានបំណងធ្វើឱ្យការបង្ហាត់បង្រៀនឱ្យរឹតតែល្អប្រសើរ និងការរៀនបានសម្រេចជោគជ័យនៃសិស្សានុសិស្ស រៀននៅរដ្ឋម៉ាស្សាឈូសិត ដោយយោងទៅតាមលក្ខខណ្ឌរៀនសូត្រនៃ*គំរោងកម្មវិធីសិក្សា* ។

- ក្រសួងសិក្សាធិការបឋមភូមិ និងទុតិយភូមិប្រើលទ្ធផល MCAS ដើម្បីវាស់ពីការចម្រើនលូតលាស់នៃសាលារៀន ប្រយោជន៍ឱ្យសិស្សទាំងអស់បានសម្រេចក្នុងភាពជំនាញផ្នែកអក្សរសិល្ប៍អង់គ្លេស (ELA) និង គណិតសាស្រ្ត ។ ការសម្រេចជាគជ័យក្នុងគោលបំណងនេះនៅឆ្នាំ 2014 គឺជាគោលដៅយ៉ាងសំខាន់នៃច្បាប់រដ្ឋសហព័ន្ធ ដែលចែងថាមិនត្រូវទុកឱ្យកុមារណារៀននៅក្រោយកម្មវិធីឡើយ ។ រៀងរាល់ឆ្នាំ រដ្ឋបញ្ចេញផ្សាយការសម្រេចពី Adequate Yearly Progress [ការចម្រើនលូតលាស់គ្រប់គ្រាន់ប្រចាំឆ្នាំ] (AYP) សម្រាប់សាលារដ្ឋ និងមណ្ឌល ក្នុងរដ្ឋ និងសម្រាប់ក្រុមសិស្សតូចៗនៅតាមសាលា និង តាមមណ្ឌលនិមួយៗ ។ សិស្សក្នុងក្រុមតូចៗរាប់ទាំង :

    - សិស្ស ឬអតីតសិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់
    - សិស្សដែលរៀនធ្លាក់
    - សិស្សដែលមានចំណូលទាប
    - សិស្សអាហ្វ្រិកអាមេរិកកាំង/ស្បែកខ្មៅ សិស្សអាស៊ី សិស្សអេស្ប៉ាញ៉ុល/អាមេរិកខាងត្បូង សិស្សជនជាតិដើមអាមេរិកកាំង សិស្សស្បែកស និងជនជាតិច្រើន-សិស្សមិនមែនជាជនជាតិអេស្ប៉ាញ៉ុល/អាមេរិកខាងត្បូង

# V. តើលទ្ធផលនៃ MCAS រាយការណ៍យ៉ាងដូចម្តេច ?

មាតាបិតារបស់សិស្សម្នាក់ៗក្នុងថ្នាក់ទី 3 រហូតដល់ទី 8 និងទី 10 ទទួលបាននូវ *សេចក្តីណែនាំសម្រាប់មាតាបិតា និងអាណាព្យាបាល* ដែលបង្ហាញពីលទ្ធផលសម្រាប់ការប្រឡង MCAS 2008 នានិទាឃរដូវទាំងអស់ដែលកូនរបស់ពួកគេប្រឡង ។

មាតាបិតារបស់សិស្សថ្នាក់ទី 9 ដែលបានចូលរួមក្នុងការប្រឡងវិស័យជីវវិទ្យា គីមីវិទ្យា រូបវិទ្យាមូលដ្ឋាន ឬបច្ចេកវិទ្យា/វិស្វកម្មនានិទាឃរដូវឆ្នាំ 2008 ទទួលបាននូវ *សេចក្តីណែនាំសម្រាប់មាតាបិតា និងអាណាព្យាបាល* ព្រមជាមួយនិងលទ្ធផលសម្រាប់ការប្រឡងដែលបានធ្វើដោយកូនរបស់ពួកគេ ។ ឆ្នាំនេះក្រសួងកំពុងធ្វើការសាកល្បងទម្រង់រាយការណ៍ថ្មីសម្រាប់ការប្រឡងថ្នាក់ទី 9 តែប៉ុណ្ណោះ ។ ព័ត៌មានពាក់ព័ន្ធនឹងរបាយការណ៍រៀបចំជាថ្មីនេះ ត្រូវបានផ្តល់ជូននៅផ្នែក ក រហូតដល់ផ្នែក ឃ ខាងក្រោម ។

*Parent/Guardian Reports* [*សេចក្តីណែនាំសម្រាប់មាតាបិតា និងអាណាព្យាបាល*] មិនត្រូវបានផ្តល់ឱ្យសម្រាប់ការប្រឡងប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រសង្គម ឬប្រវត្តិសាស្ត្រអាមេរិកនោះទេ ។ លទ្ធផលពីការប្រឡងទាំងនេះ មិនត្រូវបានរាយការណ៍ជាផ្លូវការនោះទេនាឆ្នាំនេះ ។ ជាងនេះ ទៀត ពួកវាត្រូវបានប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធលទ្ធផលនៃសំណួរប្រឡង ។ លទ្ធផលសម្រាប់ចំណុចដែលបានជ្រើសរើសពីការប្រឡងប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រសង្គម និងប្រវត្តិសាស្ត្រអាមេរិក ត្រូវបានផ្តល់ឱ្យសាលាសម្រាប់តែគោលបំណងវិភាគតែ ប៉ុណ្ណោះ ។

## ក. ផ្នែកទី I: ពិន្ទុរបស់កូនលោក-អ្នក

សម្រាប់សិស្សក្នុងថ្នាក់ទី 4–8 និងទី 10 ផ្នែកទី I នៃ*របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល* រាយបង្ហាញពីមុខវិជ្ជាប្រឡងតាមថ្នាក់របស់កូន លោក-អ្នក កម្រិតពិន្ទុកូនរបស់លោក-អ្នក ក្នុងមុខវិជ្ជានិមួយៗ ពិន្ទុកូនរបស់លោក-អ្នក ក្នុងមុខវិជ្ជានិមួយៗ និងលំដាប់ពិន្ទុប្រហាក់ប្រហែល របស់កូនលោក-អ្នក ។

សម្រាប់សិស្សក្នុងថ្នាក់ទី 3 តែប៉ុណ្ណោះ ផ្នែកទី I នៃរបាយការណ៍រាយបង្ហាញពីមុខវិជ្ជាដែលបានប្រឡង និងកម្រិតលទ្ធផលរបស់កូនលោក-អ្នកក្នុងមុខវិជ្ជានិមួយៗ ។ វាក៏បង្ហាញពីទីតាំងពិន្ទុរបស់កូនលោក-អ្នកនៅក្នុងលំដាប់កម្រិតពិន្ទុផងដែរ ។

សម្រាប់សិស្សក្នុងថ្នាក់ទី 9 តែប៉ុណ្ណោះ ផ្នែកទី I នៃរបាយការណ៍មាននូវព័ត៌មានជាក់លាក់ក្នុងទម្រង់ដែលត្រូវបានរៀបចំឡើង ដើម្បីជួយអ្នកយល់ច្បាស់ពីលទ្ធផលកូនរបស់លោក-អ្នក ។ អត្ថបទពន្យល់ភ្ជាប់ជាមួយការបង្ហាញតាមក្រាហ្វិកពីពិន្ទុ កម្រិតពិន្ទុ និងលំដាប់ពិន្ទុប្រហាក់ប្រហែលរបស់កូនលោក-អ្នក ។

## កម្រិតលទ្ធផលនៃការប្រឡង

កម្រិតលទ្ធផលនៃការប្រឡងភ្ជាប់លទ្ធផលរបស់សិស្សទៅនឹងលក្ខខណ្ឌរៀនសូត្រក្នុង*គំរោងកម្មវិធីសិក្សា* ។ គ្រូបង្រៀនតាមថ្នាក់ អ្នកអប់រំក្នុងក្រសួង សាស្ត្រាចារ្យឧត្តមសិក្សា និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ បានចូលរួម ជាគណៈកម្មាធិការតែងតាំងមាត្រដ្ឋានសម្រាប់ការប្រឡងថ្មីនីមួយៗ ដើម្បីសំគាល់អំពីពិន្ទុប្រឡងសរុបដែលទាបបំផុត ជាប់ទាក់ទងជាមួយនឹងកម្រិតការបំពេញសិក្សាលទ្ធផល និមួយៗ ។ ក្រសួងប្រើប្រាស់មាត្រដ្ឋានដែលត្រូវបានបង្កើតឡើង ដើម្បីរាយការណ៍ពីកម្រិតលទ្ធផលនៃការប្រឡងសម្រាប់ការប្រឡងនិមួយៗ ។

ពីថ្នាក់ទី4 រហូតដល់ថ្នាក់ទី8 គេរាយការណ៍លទ្ធផល MCAS ដោយអនុលោមទៅតាមកម្រិតសិក្សាបួន យ៉ាង: ***Advanced*** [***ជឿនលឿន***] ***Proficient*** [***ជំនាញ***] ***Needs Improvement*** [***ខំរៀនថែម ទៀត***] និង ***Warning*** [***ព្រមាន***] ។ សម្រាប់ការប្រឡងឡើងថ្នាក់ទី 10 ELA និងគណិតសាស្ត្រ និងសម្រាប់ការប្រឡង STE ថ្នាក់មធ្យមសិក្សា កម្រិតសិក្សាមាន ***ជឿនលឿន ជំនាញ ខំរៀនថែមទៀត*** និង ***Failing*** [***ធ្លាក់***] ។ សម្រាប់ការប្រឡង ELA និងគណិតសាស្ត្រថ្នាក់ទី3 កម្រិតលទ្ធផលនៃការប្រឡងគឺ ***Above Proficient*** [***លើសពីជំនាញ***] ***ជំនាញ ខំរៀនថែមទៀត និងព្រមាន*** ។ ការវាយតម្លៃជម្រើសរបស់ MCAS រួមមានកម្រិតលទ្ធផល ***Progressing*** [***រីកចម្រើន***] ***Emerging*** [***កើនឡើង***] និង ***Awareness*** [***ចេះ***] ។

*ផ្នែកខាងក្រោយនៃសេចក្ដីណែនាំសម្រាប់មាតាបិតា និងអាណាព្យាបាល* ផ្ដល់នូវនិយមន័យទូទៅនៃកម្រិតលទ្ធផលរបស់ MCAS និង ការវាយតម្លៃជម្រើសរបស់ MCAS ។

## មាត្រដ្ឋានពិន្ទុ

សម្រាប់ថ្នាក់ទី 4 និងខ្ពស់ជាងនេះ លំដាប់មាត្រដ្ឋានពិន្ទុរបស់សិស្សមានពី 200 ទៅ 280 ។ ការប្រើមាត្រដ្ឋានពិន្ទុ ជួយសម្រួលក្នុងការបកស្រាយលទ្ធផល MCAS ក្នុងចំណោមការប្រឡង និងឆ្នាំទាំងឡាយ ។ ឧទាហរណ៍ មាត្រដ្ឋានពិន្ទុ 240 នៃការប្រឡង MCAS វិស័យវិជ្ជាណាមួយ ចង្អុលឱ្យឃើញជានិច្ចថា ពិន្ទុរបស់សិស្សឋិតនៅក្រោមកម្រិតការបំពេញសិក្សា *ភាពជំនាញ* ។ មិនមានមាត្រដ្ឋានពិន្ទុសម្រាប់សិស្សថ្នាក់ទី 3 នោះទេ ។ ពិន្ទុសុទ្ធរបស់ពួកគេ ត្រូវបានផ្ដល់ជូននៅក្នុងផ្នែក II នៃរបាយការណ៍នេះ ។

**រង្វង់មាត្រដ្ឋានពិន្ទុនៃការប្រឡង MCAS ឆ្នាំ 2008 ថ្នាក់ទី 4 និងខ្ពស់ជាងនេះ**

| កម្រិតលទ្ធផល | មាត្រដ្ឋានពិន្ទុ |
|---|---|
| *ជឿនលឿន* | 260–280 |
| *ជំនាញ* | 240–258 |
| *ខំរៀនថែមទៀត* | 220–238 |
| *ព្រមាន* (ថ្នាក់ទី 4 ទៅទី 8)<br>*ធ្លាក់* (ថ្នាក់ទី 10 និងវិទ្យាសាស្ត្រសង្គម និងបច្ចេកវិទ្យា/វិស្វកម្មថ្នាក់មធ្យមសិក្សា) | 200–218 |

## ការបង្ហាញពិន្ទុ និង លំដាប់ពិន្ទុប្រហាក់ប្រហែល (ថ្នាក់ទី 4–8 និងទី 10)

ចំណែកនៃផ្នែកទី I នេះបង្ហាញពីពិន្ទុនៃកូនរបស់លោក-អ្នកសម្រាប់មុខវិជ្ជានិមួយៗ និងជួរកម្រិតនៃពិន្ទុដែលអាចនឹងមាន ដោយប្រើសញ្ញាគំនូសឆ្នូតពណ៌ប្រផេះ ដែលមានបន្ទាត់បញ្ឈរនៅចំកណ្ដាល ។ បន្ទាត់បញ្ឈរតំណាង រង្វង់មាត្រដ្ឋានពិន្ទុនៃកូនរបស់លោក-អ្នក ក្នុងការប្រឡងនិមួយៗ ។ សញ្ញាចម្រឹងផ្ដេកបង្ហាញរង្វង់ពិន្ទុដែល កូនរបស់លោក-អ្នកប្រហែលនឹងទទួល បើកូនលោក-អ្នកប្រឡងច្រើនដង ។ លំដាប់ត្រូវបានបង្ហាញពាក់ព័ន្ធនឹងកម្រិតលទ្ធផល MCAS ។

## ការបង្ហាញពិន្ទុរបស់សិស្សនៅក្នុងលំដាប់កម្រិតលទ្ធផល (ថ្នាក់ទី 3)

ចំណែកនៃផ្នែកទី I នេះបង្ហាញពីទីតាំងពិន្ទុកូនរបស់លោក-អ្នកនៅលើលទ្ធផលប្រឡងនិមួយៗពាក់ព័ន្ធនឹងលំដាប់កម្រិតលទ្ធផល MCAS ។

## ការបង្ហាញពិន្ទុ និងលំដាប់ពិន្ទុប្រហាក់ប្រហែល (ថ្នាក់ទី 9)

មាត្រដ្ឋានពិន្ទុរបស់កូនលោក-អ្នកសម្រាប់ការប្រឡង STE ដែលបានរាយបង្ហាញនៅក្នុងចំណងជើងរបាយការណ៍ ត្រូវបានគូសបង្ហាញនៅក្នុងប្រអប់ផ្នែកខាងឆ្វេងខាងលើផ្នែកទ I ។ ប្រអប់នេះក៏ផ្ដល់ជូននូវព័ត៌មានថាតើកូនរបស់អ្នកបានបំពេញតាមបទដ្ឋាន MCAS សម្រាប់ការប្រឡង STE ថ្នាក់មធ្យមសិក្សាដែរឬអត់ ។ សញ្ញាព្រួញខ្មៅនៅផ្នែកខាងស្ដាំប្រអប់ចង្អុលទៅកាន់ពិន្ទុកូនរបស់អ្នកនៅក្នុងការបង្ហាញតាមក្រាហ្វិក ។ របារប្រផេះស្តើងខាងលើ និងក្រោមពិន្ទុកូនរបស់អ្នក ចង្អុលបង្ហាញលំដាប់ពិន្ទុដែលកូនរបស់អ្នកប្រហែលជាអាចនឹងទទួលបាន ប្រសិនបើកូនរបស់លោក-អ្នកទទួលយកការប្រឡងច្រើនដង ។

## ខ. *ផ្នែកទី II: ព័ត៌មានអំពីលទ្ធផលរបស់កូនលោក-អ្នកចំពោះសំណួរប្រឡង MCAS*

ផ្នែកទី II នៃ*របាយការណ៍សម្រាប់មាតាបិតា/អាណាព្យាបាល* បង្ហាញពីរបៀបដែលកូនរបស់អ្នកឆ្លើយរាល់សំណួរ ប្រឡងទូទៅគ្រប់សំណួរក្នុងមុខវិជ្ជាដែលបានប្រឡង ។ ជួរដំបូងនៃផ្នែកនេះ បង្ហាញពីលេខ ឬអក្សរកាត់សម្រាប់សំណួរនិមួយៗ ។ តារាងខាងក្រោមបង្ហាញពីចំនួនសំណួរសម្រាប់ថ្នាក់ និងមុខវិជ្ជានិមួយៗ ។

| ការប្រឡង MCAS ឆ្នាំ 2008<br>ចំនួនសំណួរទូទៅសម្រាប់ថ្នាក់និមួយៗ និង មុខវិជ្ជានិមួយៗ | | | |
|---|---|---|---|
| ថ្នាក់ | អក្សរសាស្ត្រអង់គ្លេស | គណិតវិទ្យា | វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម |
| 3 | 42 | 35 | -- |
| 4 | 40 បូក តែងសេចក្តី | 39 | -- |
| 5 | 40 | 39 | 39 |
| 6 | 40 | 39 | -- |
| 7 | 40 បូក តែងសេចក្តី | 39 | -- |
| 8 | 40 | 39 | 39 |
| 10 | 40 បូក តែងសេចក្តី | 42 | -- |
| មធ្យមសិក្សា | -- | -- | 45 (ជីវវិទ្យា)<br>45 (គីមីវិទ្យា)<br>45 (រូបវិទ្យាមូលដ្ឋាន)<br>45 (បច្ចេកវិទ្យា/វិស្វកម្ម) |

ចំនួនសំណួរមានខុសគ្នាពីថ្នាក់មួយ និងមុខវិជ្ជាមួយទៅមួយទៀត ។ ដោយផ្អែកតាមចំនួន និងប្រភេទសំណួរនៅក្នុងការប្រឡង របាយការណ៍របស់កូនលោក-អ្នកនឹងមាននូវចំណាត់ថ្នាក់រាយការណ៍ និង ចន្លោះពិន្ទុ ។

ការបកស្រាយលេខកូដដែលប្រើប្រាស់ក្នុងចំណាត់ថ្នាក់រាយការណ៍ និងជួរពិន្ទុ សូមមើលចំណងជើង ដែលមាននៅទំព័រខាងក្រោយ *របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល* ។

សំណួរពិតប្រាកដ និង ចម្លើយត្រឹមត្រូវ អាចមើលបានតាមវ៉ិបសាយរបស់ក្រសួង www.doe.mass.edu/mcas/testitems.html ក្នុងឯកសារ *Release of Spring 2008 MCAS Test Items* [*ការបញ្ចេញផ្សាយមុខវិជ្ជាឱ្យប្រឡងនារដូវផ្ការីកឆ្នាំ 2008 របស់ MCAS*] ។ សម្ភារៈពីឯកសារនេះអាចជ្រើសរើស និង បោះពុម្ពចេញដោយកម្រិតថ្នាក់ និង មុខវិជ្ជានិមួយៗ ។

សម្រាប់សិស្សថ្នាក់ទី 3 តែប៉ុណ្ណោះ ជូរឈរនៅខាងស្តាំក្នុងផ្នែកទ II រាយបង្ហាញពីចំនួនពិន្ទុជួរដេកសរុប ដែលកូនរបស់លោក-អ្នកបានទទួលសម្រាប់មុខវិជ្ជាដែលបានប្រឡងនិមួយៗ ។

## *គ. ផ្នែកទី III: តើពិន្ទុរបស់កូនលោក-អ្នក ប្រៀបធៀបទៅនឹងពិន្ទុសាលា មណ្ឌល និងរដ្ឋយ៉ាងដូចម្ដេចដែរ ?*

ផ្នែកនៃ*របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល* នេះ ប្រៀបធៀបការសិក្សារបស់កូនលោក-អ្នកក្នុងការប្រឡងវិស័យមុខវិជ្ជានិមួយៗ ជាមួយមធ្យមភាគនៃការសិក្សារបស់សិស្សរៀនថ្នាក់ដូចគ្នានៅសាលារៀនរបស់កូនលោក-អ្នកនៅសាលាមណ្ឌល តំបន់របស់កូនលោក-អ្នក និងនៅរដ្ឋទាំងអស់ ។ សម្រាប់ការប្រឡង STE ថ្នាក់មធ្យមសិក្សា មុខវិជ្ជាទាំងបួនត្រូវបានផ្ដុំគ្នានៅក្នុងផ្នែកនេះ ហើយការប្រៀបធៀប ផ្អែកលើសិស្សនៅក្នុងថ្នាក់នៅឆ្នាំ 2010 សម្រាប់របាយការណ៍ថ្នាក់ទី 10 និងទៅលើសិស្សក្នុងថ្នាក់នៅឆ្នាំ 2011 សម្រាប់របាយការណ៍ថ្នាក់ទី 9 ។

កម្រិតលទ្ធផលរបស់កូនលោក-អ្នកពីផ្នែកទី I ត្រូវបានបង្កើតនៅផ្នែកខាងឆ្វេងដៃនៃក្រាហ្វនិមួយៗ (A = ជឿនលឿន , P+ = លើជំនាញ [សម្រាប់តែថ្នាក់ទី 3] , P = ជំនាញ , NI = ខំរៀនថែមទៀត ,  W = ព្រមាន , F = ធ្លាក់ [សម្រាប់តែថ្នាក់ទី 10 និងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្មថ្នាក់មធ្យមសិក្សាប៉ុណ្ណោះ]) ។
បន្ទាត់ត្រង់នៅកណ្ដាលក្រាហ្វបង្ហាញពី ភាគរយសិស្សក្នុង សាលាកូនលោក-អ្នក (SCH) និង តំបន់ (DIS) និង ក្នុងរដ្ឋ (STA) ដែលអនុវត្តចំពោះកម្រិតលទ្ធផលនិមួយៗ ។

## *ឃ. ផ្នែកទី IV: ព័ត៌មានបន្ថែម*

## សម្រាប់ថ្នាក់ទី 4 ទី 7 និង ទី 10 ប៉ុណ្ណោះ : ការពណ៌នាស្ដីពីការបំពេញកិច្ចការអនុវត្តនផ្នែកសរសេររបស់កូនលោក-អ្នក

សិស្សថ្នាក់ទ 4 ទី 7 ទី 10 ត្រូវបានដាក់ឱ្យប្រឡងតែងសេចក្ដី (ការសរសេរ) និងអំណាន ។ លទ្ធផលនៃការប្រឡងទាំងពីរត្រូវបានគេដាក់បញ្ចូលគ្នា ដើម្បីឱ្យឈានដល់កម្រិតការអនុវត្តមួយ និងមាត្រដ្ឋានពិន្ទុ ELA សម្រាប់សិស្សម្នាក់ៗ ។ សម្រាប់ចំណាត់ថ្នាក់ទាំងនេះ ផ្នែកទី IV នៃរបាយការណ៍សម្រាប់អាណាព្យាបាល/ឪពុកម្ដាយ ផ្ដល់នូវការពណ៌នាពីការអនុវត្តការសរសេររបស់កូនរបស់លោក-អ្នក ។ ការពណ៌នាដែលពាក់ព័ន្ធនឹងពិន្ទុកូនរបស់លោក-អ្នកសម្រាប់ការបង្កើតប្រធានបទ ត្រូវបានបង្ហាញនៅប្រអប់ខាងលើបំផុត ហើយការពណ៌នាណាដែលពាក់ព័ន្ធនឹងពិន្ទុរបស់កូនរបស់លោក-អ្នកសម្រាប់ការប្រើប្រាស់ការសន្ទនាភាសាអង់គ្លេសតាមក្បួនខ្នាត ត្រូវបានបង្ហាញនៅក្នុងប្រអប់ខាងក្រោមបំផុតក្នុងផ្នែកនៃរបាយការណ៍នេះ ។

## សម្រាប់ថ្នាក់ទី 9 ប៉ុណ្ណោះ: ភាគរយនៃសិស្សនៅក្នុងថ្នាក់នាឆ្នាំ 2011 ដែលបានចូលរួមក្នុងការប្រឡង STE ថ្នាក់មធ្យមសិក្សា

ក្រាហ្វឈរនៅក្នុងផ្នែកទី IV នេះ បង្ហាញពីភាគរយសិស្សនៅក្នុងថ្នាក់ឆ្នាំ 2011 ដែលបានចូលរួមក្នុងការប្រឡង MCAS វិស័យជីវវិទ្យា គីមីវិទ្យា រូបវិទ្យាមូលដ្ឋាន ឬបច្ចេកវិទ្យា/វិស្វកម្មនៅក្នុងនិទាឃរដូវឆ្នាំ 2008 ។ សិស្សនៅក្នុងថ្នាក់ទី 9 មានសិទ្ធិចូលរួមក្នុងការប្រឡង STE ថ្នាក់មធ្យមសិក្សា ប្រសិនបើពួកគេបានបញ្ចប់វគ្គសិក្សាក្នុងមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាទាំងបួនដែលបានប្រឡង និងជ្រើសរើសចូលរួមប្រឡង ។

## *ង. តើព័ត៌មានអ្វីខ្លះដែលសេចក្ដីណែនាំសម្រាប់មាតាបិតា និងអាណាព្យាបាលផ្ដល់ឱ្យប្រសិនបើកូន របស់អ្នកបានចូលរួមក្នុងការវាយតម្លៃជម្រើស ?*

ប្រសិនបើកូនលោក-អ្នកទទួលយកការវាយតម្លៃជ្រើសរើស *របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល* បង្ហាញពីកម្រិតការសិក្សា តែមិនមែនជាមាត្រដ្ឋានពិន្ទុសម្រាប់ការប្រឡងតាមបទដ្ឋាននោះទេ ។ ព័ត៌មានលំអិតផ្សេងទៀតអំពីការសិក្សារបស់កូនលោក-អ្នកចំពោះការវាយតម្លៃជ្រើសរើស ត្រូវបានផ្ដល់ក្នុងរបាយការណ៍ផ្សេងទៀត សម្រាប់មាតាបិតានិងអាណាព្យាបាលគឺ *MCAS-Alt Parent/Guardian Report* [*របាយការណ៍សម្រាប់មាតាបិតាស្ដីពីជម្រើស MCAS*] ។

### ច. *ក្នុងលក្ខខណ្ឌបែបណាដែលកូនសិស្សមួយណា មិនបានទទួលពិន្ទុ* **MCAS ?**

- បើកូនរបស់លោក-អ្នកឈប់មិនបានមកប្រឡង ដោយមានសំបុត្រពេទ្យដោះសារ *របាយការណ៍សម្រាប់មាតាបិតា និង អាណាព្យាបាល* នឹងបង្ហាញពីកម្រិត *medically excused* [*ព្យាបាលដែលបានដោះសារ*] នោះ ។
- បើកូនរបស់លោក-អ្នកឈប់មិនបានមកប្រឡង និងបង្កើតការប្រឡងដោយមិនមានការដោះសារជាឯកសារពេទ្យ *របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល* នឹងបង្ហាញពីកម្រិត *absent* [*អវត្តមាន*] នោះ ។
- បើសាលារបស់លោក-អ្នក បង្ហាញថាកូនរបស់លោក-អ្នកជាសិស្សមានជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP) ដែលបានចុះឈ្មោះរៀន នៅសាលារៀនសហរដ្ឋអាមេរិកជាលើកដំបូងក្រោយថ្ងៃទី 1 ខែ មិនា ឆ្នាំ 2007 *របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល* នឹងបង្ហាញពីកម្រិតលទ្ធផល *LEP* នោះ ។ របាយការណ៍ នេះក៏ផ្តល់ឱ្យនូវការវិភាគចំណុចសម្រាប់ផ្នែកទាំងឡាយនៃការប្រឡង ដែលកូនរបស់លោក-អ្នកចង់បានផងដែរ ។
- ក្នុងករណីមួយចំនួនតូច *របាយការណ៍សម្រាប់មាតាបិតា និងអាណាព្យាបាល* អាចបញ្ជាក់ថា កម្រិតការសិក្សាគឺ *Incomplete* [*មិនពេញលេញ*] ឬ *Transferred* [*ផ្ទេរ*] ។ សូមទាក់ទងសាលារបស់កូនលោក-អ្នក ប្រសិនបើ លោក-អ្នកចង់បានព័ត៌មានបន្ថែមទៀតពាក់ព័ន្ធនឹងការកំណត់នេះ ។

# VI. *តើខ្ញុំអាចរកព័ត៌មានថែមទៀតនៅឯណា ?*

### ក. *របាយការណ៍បន្ថែមដែលមាន*

ប្រភពជំនួយដែលបានចុះរាយផ្នែកនេះ បានត្រូវផ្តល់ទៅសាលានានា និងមណ្ឌល បន្ទាប់ពីបានដាក់ឱ្យប្រឡង MCAS ។ សូមទាក់ទងទៅសាលាដែលកូនលោក-អ្នកបានប្រឡង MCAS សម្រាប់ការទទួលប្រភពជំនួយទាំងនេះ ។

- ELA Composition [តែងសេចក្តី ELA] (សម្រាប់តែថ្នាក់ទី 4 ទី 7 និង ទី 10)
  អត្ថបទតែងសេចក្តីអក្សរសិល្ប៏ភាសាអង់គ្លេស (ELA) របស់សិស្ស ត្រូវបានបញ្ជូនទៅសាលារៀន ជាទ្រង់ទ្រាយអេឡិចត្រូនិកពីវ៉ិបសាយ ។ ពួកវាមានផ្តល់ជូនសម្រាប់មាតាបិតា និង អាណាព្យាបាលតាមសំណូមពរ ។
- *School* and *District Reports* [*របាយការណ៍សាលា* និង *តំបន់*]
  របាយការណ៍ទាំងនេះ អាចមានតាមអ៊ិនធ័រណេត និងផ្តល់ព័ត៌មានអំពីក្រុមតូចៗនៃសិស្សដែលបានប្រឡង ការចែកលទ្ធផលតាមមាត្រដ្ឋានពិន្ទុមួយរយៈពេល លទ្ធផលកម្រិតការសិក្សា និងការប្រៀបធៀបលទ្ធផលបីឆ្នាំ ។
- *Test Item Analysis Report Summaries* [*សេចក្តីសង្ខេបរបាយការណ៍ការវិភាគមុខវិជ្ជាឱ្យប្រឡង*]
  របាយការណ៍ទាំងនេះ បង្ហាញពីចំណុចពិន្ទុជាមធ្យម និង ភាគរយនៃការឆ្លើយតបសរុបរបស់សិស្សសម្រាប់សំណួររើសចម្លើយ សំណួរ-ចម្លើយខ្លី ឬសំណួរ-ចម្លើយចំហរ ។

### ខ. *ប្រភពជំនួយផ្សេងទៀត*

ការបោះពុម្ពផ្សាយដែលមានចុះរាយក្នុងផ្នែកនេះ គឺមានដាក់ជូននៅលើវ៉ិបសាយរបស់ក្រសួង ។ ឯកសារជាច្រើន ក៏មាននៅឯសាលានៃកូនរបស់លោក-អ្នកផងដែរ ។

- *Release of Spring 2008 MCAS Test Items [ការបញ្ចេញផ្សាយមុខវិជ្ជាឱ្យប្រឡងនារដូវផ្ការីកឆ្នាំ 2008 របស់ MCAS*] ដែលអាចទទួលយកតាម www.doe.mass.edu/mcas/testitems.html មានសំណួរក្នុងការប្រឡង MCAS ឆ្នាំ 2008 ដែលគេប្រើដើម្បីកំណត់លទ្ធផលសិស្ស ។
- *Requirements for the Participation of Students with Disabilities in MCAS [សេចក្តីតម្រូវក្នុងការចូលរួមនៃសិស្សដែលរៀនធ្លាក់ក្នុង MCAS*] ដែលអាចទទួលបានតាម www.doe.mass.edu/mcas/participation ផ្តល់ចំណុចសំខាន់នៃសេចក្តីតម្រូវខាងការចូលរួម និង ការសម្របសម្រួលអនុញ្ញាតសម្រាប់សិស្សដែលរៀនធ្លាក់ ។
- *Requirements for the Participation of Students with Limited English Proficiency in MCAS and MEPA [សេចក្តីតម្រូវក្នុងការចូលរួមប្រឡងនៃសិស្សដែល មានភាពជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ក្នុង MCAS និង MEPA*] អាចទទួលយកតាម www.doe.mass.edu/mcas/participation ផ្តល់ចំណុចសំខាន់ពីសេចក្តីតម្រូវសម្រាប់ ការចូលរួមនៃសិស្សដែលមានភាពជំនាញភាសាអង់គ្លេសមិនគ្រប់គ្រាន់ (LEP) ។
- *Curriculum Frameworks* in *English Language Arts, Mathematics, Science and Technology/Engineering*, and *History and Social Science [គំរោងកម្មវិធីសិក្សាអំពីអក្សរសិល្ប៍អង់គ្លេស គណិតសាស្ត្រ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា* និង *ប្រវត្តិសាស្ត្រ និង វិទ្យាសាស្ត្រសង្គម*] អាចទទួលយកតាម www.doe.mass.edu/frameworks/current.html ពិពណ៌នាពីអ្វីៗដែលសិស្សគួរដឹង និងរៀបរាប់ផ្អែកតាមរយៈពេលនៃកម្រិតថ្នាក់របស់ពួកគេ និងរៀបរាប់នៅកម្រិតថ្នាក់នីមួយៗ ។
- ដំណើរការ MCAS Performance Appeals [សំណើលទ្ធផល MCAS] អាចឱ្យសិស្សបកស្រាយ តាមរយៈការងារនៅផ្ទះរបស់ពួកគេ ដែលពួកគេបំពេញបាន ឬលើសបទដ្ឋានចាំបាច់ក្នុងភាសាអង់គ្លេស និង/ឬគណិតសាស្ត្រ បើទោះបីជាពួកគេមិនអាចជាប់ការប្រឡង ឬការប្រឡងសាជាថ្មីក៏ដោយ ។ វាត្រូវបានរំពឹងទុកថា ប្រធាននេះ នឹងទទួលបានសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្មថ្នាក់មធ្យមសិក្សាក្នុងកំឡុងឆ្នាំសិក្សា 2008–2009 ។ ប្រភពមូលដ្ឋានសម្រាប់ព័ត៌មានពាក់ព័ន្ធសំណើលទ្ធផល MCAS មាននៅលើវិបសាយ www.doe.mass.edu/mcasappeals ។

## *គ. តើលោក-អ្នកអាចធ្វើអ្វីដើម្បីជួយកូនលោក-អ្នក ?*

ជំនួយរបស់លោក-អ្នកចំពោះកូន មានភាពសំខាន់ណាស់ក្នុងពេលឥឡូវនេះ និង ពេលអនាគត ក្នុងការសិក្សាខាងអាជីពរបស់គេ ។ នេះគឺជាពាក្យរំលឹកខ្លះៗ សម្រាប់ជួយរៀបចំកូនរបស់លោក-អ្នក ដើម្បីប្រឡង MCAS ក្រោយទៀត :

- និយាយជាមួយគ្រូៗរបស់កូនលោក-អ្នកឱ្យបានទៀងទាត់ ក្រែងលោក-អ្នកអាចធ្វើការអ្វីខ្លះនៅផ្ទះ ដើម្បីជួយកូនលោក-អ្នករៀននៅសាលា ។
- ធ្វើឱ្យប្រាកដថាកូនលោក-អ្នក ចូលដំណេកឱ្យបានគ្រប់គ្រាន់ បរិភោគបានត្រឹមត្រូវ ហើយទៅសាលារៀនឱ្យទាន់ពេលវេលាជារៀងរាល់ថ្ងៃ ។ ចូរបញ្ជូនកូនរបស់លោក-អ្នកទៅសាលារៀបចំសិក្សា ។
- ពិភាក្សាជាមួយកូនរបស់លោក-អ្នក អំពីមុខវិជ្ជាណាដែលត្រូវការធ្វើឱ្យមានការជឿនលឿនថែមទៀត ។ ពិភាក្សាថាតើកូនរបស់លោក-អ្នកគិតថាតើមានការរីកចម្រើនឡើងដែរទេ ។ ប្រសិនបើមានចម្លើយថា មិនមាន លោក-អ្នកត្រូវតែរកមូលហេតុ ។
- សួរកូនលោក-អ្នកអំពីកិច្ចការសាលាដែលយកមកធ្វើនៅផ្ទះ ហើយត្រូវប្រគល់ឱ្យគ្រូវិញនៅពេលថ្ងៃស្អែក ឬ សប្តាហ៍ក្រោយ ហើយធ្វើឱ្យប្រាកដថាកិច្ចការនោះបានធ្វើចប់សព្វគ្រប់ ។
- សួរនាំកូនរបស់លោក-អ្នក ឱ្យពន្យល់អំពីមុខវិជ្ជាដែលគេកំពុងតែរៀន ។ ការសន្ទនានេះ អាចជួយលោក-អ្នកឱ្យដឹងអំពីការវិវត្តន៍នៃការរៀនសូត្ររបស់កូនលោក-អ្នក ហើយជួយកូនរបស់លោក-អ្នកឱ្យចាំអំពី វិជ្ជាដែលគេបានរៀនសូត្រ ។
- បើសិនជាកូនលោក-អ្នកជាសិស្សដែលរៀនធ្លាក់ សួរគ្រូៗរបស់គេថាតើ MCAS អាចជួយដាក់កូនលោក-អ្នកទៅនឹងផែនការ IEP ឬក៏ 504 សមត្រឹមត្រូវជាយ៉ាងណាដែរ ។
- ជួយកូនលោក-អ្នកហាត់រៀនសំណួរការប្រឡង MCAS ហើយមើលសាឡើងវិញជាមួយគ្នា ដើម្បីឱ្យលោក-អ្នក និងកូនលោក-អ្នកអាចចេះដោយសេចក្តីសង្ឃឹម ។

**Khmer version**